**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិបាលកិច្ចវិស័យមីក្រូហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើត **គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ** ដែលសរសេរជាអក្សរកាត់ថា "គ.ម.ហ." ដើម្បីបំពេញមុខងារជាសេនាធិការឱ្យ **គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** លើការងារដឹកនាំនិងអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ នៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

**គ.ម.ហ.** មានគោលបំណងធានាស្ថិរភាពនៃវិស័យមីក្រូហិរញ្ញវត្ថុ និងចីរភាពនៃកិច្ចអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ នៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## សមាសភាពនិងភារកិច្ច

**មាត្រា៣.-**

**គ.ម.ហ.** មានសមាសភាព ដូចខាងក្រោម÷

| | |
|---|---|
| ១. ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាប្រធាន គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៣. ទេសាភិបាលធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៤. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥. តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៦. តំណាងក្រសួងកិច្ចការនារី | សមាជិក |
| ៧. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨. តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៩. តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ១០. តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ១១. អគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិកអចិន្ត្រៃយ៍ |
| ១២. តំណាងធនាគារអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៣. តំណាងសមាគមធនាគារកម្ពុជា | សមាជិក |
| ១៤. តំណាងសមាគមស្ថាប័នមីក្រូហិរញ្ញវត្ថុកម្ពុជា | សមាជិក |
| ១៥. តំណាងសហគមអភិវឌ្ឍន៍កសិកម្ម | សមាជិក |

សមាសភាពជាក់ស្ដែងនៃ **គ.ម.ហ.** ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៤.-**

**គ.ម.ហ.** មានភារកិច្ច ដូចខាងក្រោម៖

- រៀបចំនិងអនុម័តគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល
- ដឹកនាំ សម្របសម្រួល ត្រួតពិនិត្យ និងតាមដានការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យមីក្រូ-ហិរញ្ញវត្ថុ
- សម្របសម្រួល និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ពាក់ព័ន្ធការងារអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ
- ពិនិត្យនិងវាយតម្លៃរបាយការណ៍វឌ្ឍនភាពនៃវិស័យមីក្រូហិរញ្ញវត្ថុ ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល និងស្នើសុំដាក់ចេញវិធានការសម្រាប់អនុវត្តបន្ត
- បំពេញភារកិច្ចផ្សេងទៀតតាមការចង្អុលបង្ហាញរបស់ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣

## ដំណើរការការងារ

**មាត្រា៥.-**

**គ.ម.ហ.** មានរបបប្រជុំសាមញ្ញ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ព្រមទាំងអាចប្រជុំជាវិសាមញ្ញ តាមការចាំបាច់។

សមាសភាពនៃ **គ.ម.ហ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានត្រូវកោះអញ្ជើញ និងដឹកនាំការប្រជុំ **គ.ម.ហ.** តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**គ.ម.ហ.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា៦.-**

ប្រធាន **គ.ម.ហ.** អាចអញ្ជើញមន្ត្រីជំនាញ នៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ចូលរួមពិគ្រោះយោបល់ តាមការចាំបាច់។

ប្រធាន **គ.ម.ហ** .មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំ តាមការចាំបាច់។

**មាត្រា៧.-**

**គ.ម.ហ.** មានលេខាធិការដ្ឋានមួយ ជាសេនាធិការ ក្នុងការបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន។

អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាលេខាធិការដ្ឋាន នៃ **គ.ម.ហ.**។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

អនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលសមាសភាពនិងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការឥណទានសម្រាប់អភិវឌ្ឍន៍ជនបទ និងបទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ